# ប្រាំឆ្នាំក្រោយការតាំងទីលំនៅនៅលើដីថ្មី ជីវិតមានការផ្លាស់ប្តូរប្រសើរឡើងជាលំដាប់







សព្វថ្ងៃ លោក ស៊ីថាត មានគោចំនួន ៧ក្បាល។


អ្នកស្រី រឿន មុំ អង្គុយលក់ទំនិញក្នុងតូបចាប់ហួយរបស់គាត់។

លោក ម៉ៃ ស៊ីថាត និងភរិយារបស់គាត់ រឿន មុំ ជាគ្រួសារកសិករក្រីក្រគ្មានដី រស់នៅក្នុងភូមិ កសាង ឃុំចង្រ្កង ស្រុកចិត្របុរី ខេត្តក្រចេះ។ ដោយគ្មានដីសម្រាប់ធ្វើកសិកម្ម លោក ស៊ីថាត បានដើរស៊ីឈ្នួលលក់កម្លាំងពលកម្មឱ្យគេ ធ្វើការងារគ្រប់យ៉ាងឱ្យតែមានគេជួល ដូចជា ដកស្ទូង ច្រូតកាត់ ដាំ គាស់ដំឡូង ភ្ជួររាស់ ជម្រះស្មៅ លីសែង រួមទាំងការងារសំណង់ ដើម្បីបានកម្រៃសម្រាប់ទ្រទ្រង់ជីវភាព។ ក៏ប៉ុន្តែស្ថានភាពជីវភាពរស់នៅរបស់គាត់ ហាក់ពុំប្រសើរឡើងឡើយ ព្រោះប្រាក់ចំណូលដែលបានពីការលក់កម្លាំងពលកម្មរបស់គាត់ មិនទៀងទាត់ និងមិនគ្រប់គ្រាន់សម្រាប់ការចាយវាយនៅក្នុងគ្រួសារទេ។

នៅចុងឆ្នាំ២០១២ គ្រួសារលោក ស៊ីថាត និងគ្រួសារក្រីក្រគ្មានដី និងខ្វះដីផ្សេងទៀតរស់នៅក្នុងស្រុកចិត្របុរី សរុប ២.១១៩គ្រួសារ មានភព្វសំណាងបានទទួលដីសម្បទានសង្គមកិច្ចពីរាជរដ្ឋាភិបាលក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី ២ ដែលគម្រោងនេះអនុវត្តរួមគ្នាដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គាំទ្រដោយធនាគារពិភពលោក។ គាត់ទទួលបានដីលំនៅឋានទំហំ ២០ម គុណនឹង ៤០ម និងដីកសិកម្មទំហំ ១ហិកតា សម្រាប់ប្រកបរបរចិញ្ចឹមជីវិត។

ប្រាំឆ្នាំ ក្រោយការតាំងទីលំនៅ និងប្រកបរបរចិញ្ចឹមជីវិតនៅលើទឹកដីថ្មី កម្រិតជីវភាពរស់នៅរបស់គ្រួសារលោក ស៊ីថាត បានចាប់ផ្តើមមានការរីកចម្រើនប្រសើរឡើងជាលំដាប់។ ហើយបច្ចុប្បន្ន គាត់មានផ្ទះធំ ហូបឆ្អាញ់ និងចំណូលគ្រប់គ្រាន់ រស់នៅជាមួយក្រុមគ្រួសារប្រកបដោយសុភមង្គល។

លោក ស៊ីថាត បានថ្លែងដោយទឹកមុខញញឹមថា៖ «បើប្រៀបធៀបកាលពី១០ឆ្នាំមុន ជីវភាពគ្រួសាររបស់ខ្ញុំបច្ចុប្បន្ន ខុសពីមុនឆ្ងាយណាស់។ ជីវភាពរបស់ខ្ញុំប្រសើរជាងមុន ស្ទើរតែ ១០០ភាគរយ។ ឥឡូវ ខ្ញុំមានផ្ទះ មានដីស្រែ ហូបឆ្អាញ់គ្រប់គ្រាន់ ដេកលក់ស្រួល មិនខ្វល់ខ្វាយច្រើនដូចកាលពីមុនទៀតទេ។»

រៀងរាល់ឆ្នាំ លោក ស៊ីថាត ដាំស្រូវ និងដំឡូងមីបន្ទាប់ពីប្រមូលផលស្រូវ នៅលើដីកសិកម្មរបស់គាត់។ ឆ្នាំនេះ គាត់ដាំស្រូវដោយប្រើជីធម្មជាតិ ទទួលបានទិន្នផល ៣តោន។ ចំណែកឯដំឡូងមី គាត់គ្រោងប្រមូលផលនៅចុងឆ្នាំនេះ ដោយរំពឹងថា នឹងអាចលក់បានចំណូលប្រហែល ១៣លានរៀល ព្រោះតម្លៃដំឡូងឆ្នាំនេះថ្លៃជាងឆ្នាំមុនៗ។

ដោយសារលោក ស៊ីថាត ធ្លាប់មានបទពិសោធន៍ចិញ្ចឹមគោ គម្រោងបានជ្រើសរើសបញ្ជូនគាត់ទៅរៀនជំនាញជាភ្នាក់ងារពេទ្យសត្វភូមិ ដើម្បីជួយព្យាបាលសត្វនៅក្នុងភូមិ។ ជំនាញនេះ បានជួយគាត់រកប្រាក់ចំណូលបន្ថែម បានប្រហែល ៤០០.០០០រៀលក្នុងមួយខែ។

លោក ស៊ីថាត និងភរិយារបស់គាត់ មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការតស៊ូក្នុងជីវិត ដើម្បីចាកចេញពីភាពក្រីក្រ។ នៅឆ្នា ២០២០ គាត់បានបង្កើតមុខរបរអាជីវកម្មថ្មីមួយ ដោយបានចំណាយដើមទុនផ្ទាល់ខ្លួនអស់ជាង ៣.០០០ ដុល្លារ សាងសង់តូបមួយនៅចំហៀងខាងមុខផ្ទះសម្រាប់ភរិយារបស់គាត់លក់ចាប់ហួយ និងកាហ្វេ។

អ្នកស្រី មុំ បានប្រាប់ឱ្យដឹងថា សព្វថ្ងៃ មុខរបរនេះ ដំណើរការល្អ។ គាត់អាចរកចំណូលដុលបានចន្លោះពី ៨០.០០០ ទៅ១០០.០០០ រៀលក្នុងមួយថ្ងៃ៕


លោក ស៊ីថាត ចុះទៅពិនិត្យមើលស្រូវរបស់គាត់។